(https://www.instagram.com/thmeythmeynews/)

(https://www.youtube.com/c/ThmeyThmeyOnlineNews)




(https://thmeythmey.com)


















# សម្តេច ហ៊ុន ម៉ាណែត ប្រាប់អ្នកស្រាវជ្រាវឱ្យចុះប្រមូលទិន្នន័យពីមូលដ្ឋានផ្ទាល់ កុំទាញពី Google

ថ្ងៃអង្គារ ទី៤ ខែមីនា ឆ្នាំ២០២៥ ម៉ោង ៣:៤៥ នាទី រសៀល

(https://www.addtoany.com/share#url=https%3A%2F%2Fthmeythmey.com%2Fdetail%2F145312&title=%E1%9E%9F%E1%9E%98%
(/#facebook) (/#twitter) (/#email) (/#telegram) (/#linkedin)

(/#print) (/#copy_link)









*សម្តេច ហ៊ុន ម៉ាណែត ផ្តាំអ្នកស្រាវជ្រាវឱ្យចុះប្រមូលទិន្នន័យពីមូលដ្ឋានផ្ទាល់ កុំទាញពី Google*

ភ្នំពេញ៖ «បើព័ត៌មានយើងប្រមូលខុស ការសម្រេចចិត្តក៏ខុស ការរៀបចំគោលនយោបាយក៏ខុស នឹងធ្វើឱ្យយើងខាតបង់ច្រើន។ ខាតពេលវេលា ខាតធនធាន ហើយអ្វីដែលសំខាន់នោះ គឺចំណុចដែលយើងចង់អន្តរាគមន៍ជួយពិតប្រាកដ គឺត្រូវបានទុកចោល។»។ នេះជាការលើកឡើងរបស់សម្តេច ហ៊ុន ម៉ាណែត ដោយផ្តាំទៅកាន់អ្នកស្រាវជ្រាវ ក្នុងការវិភាគទិន្នន័យធ្វើគោលនយោបាយអ្វីមួយ គឺត្រូវចុះប្រមូលទិន្នន័យពី













-

ក្នុងពិធីបើក «សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០២៥ ស្តីពី យុទ្ធសាស្ត្រកំណើនថ្មីរបស់ប្រទេសកម្ពុជា ៖ អាទិភាពសម្រាប់ការអភិវឌ្ឍប្រកបដោយគុណភាពខ្ពស់ និងនិរន្តរភាព» នាព្រឹកថ្ងៃទី៤ ខែមីនា សម្តេច នាយករដ្ឋមន្ត្រី បានបញ្ជាក់ថា ការប្រមូលព័ត៌មានខុស អាចឱ្យធ្វើការអន្តរាគមន៍របស់រដ្ឋាភិបាលខុស គោលដៅ ហើយបង្កឱ្យមានបញ្ហាលើសដើម។ នេះ គឺជាកត្តាសំខាន់ក្នុងការពង្រឹងលើកិច្ចការស្រាវជ្រាវ និង ប្រមូលទិន្នន័យ ដែលរដ្ឋាភិបាលកំពុងចាត់វិធានការជានានូវសង្គតិភាព និងគុណភាព ក្នុងការរៀបចំគោល នយោបាយបន្ថែមទៀត។

សម្តេច ហ៊ុន ម៉ាណែត បានចាត់ទុកវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) គឺជាតួអង្គសំខាន់មួយលើកិច្ចការស្រាវជ្រាវ និងប្រមូលទិន្នន័យ ក្នុងការវិភាគធ្វើគោលនយោបាយអ្វីមួយ របស់រដ្ឋាភិបាល។ សម្តេច បានបញ្ជាក់ថា ៖ « នេះជារបៀបដែលរដ្ឋាភិបាលធ្វើ ដោយមិនផ្អែកទៅលើ មនុស្សម្នាក់ចេះគ្រប់នោះទេ  គឺផ្អែកទៅលើក្រុមមនុស្ស ដែលមានធនធាន បញ្ញាញាណ ជំនាញ ប្រមូលផ្តុំគ្នា ពិគ្រោះគ្នា រៀបចំជាគោលនយោបាយ ដាក់ចេញគោលនយោបាយ យើងអនុវត្ត ហើយតែងតែវាយតម្លៃ ជាប្រចាំ ដើម្បីពិនិត្យមើល។»។

ការរៀបចំគោលនយោបាយអ្វីក៏ដោយ ចំណុចដែលសំខាន់បំផុតនោះ គឺផ្តើមចេញពីការវិភាគនូវសភាព






ប្រាកដជាយកពិសោធន៍ពីនោះខ្លះធ្វើជាមូលដ្ឋាន ប៉ុន្តែត្រូវសម្របទៅតាមស្ថានភាពបច្ចុប្បន្នរបស់ប្រទេសយើង។ ស្ថានភាពដែលយើងចុះផ្ទាល់ ប្រមូលផ្ទាល់ពីប្រជាពលរដ្ឋតែម្តង។»។

សម្តេច ហ៊ុន ម៉ាណែត ប្រាប់អ្នកស្រាវជ្រាវឱ្យចុះប្រមូលទិន្នន័...
Thmey Thmey 25
Share
Facebook Watch

បើតាមប្រមុខរដ្ឋាភិបាល បើចង់ឱ្យការអនុវត្តគោលនយោបាយណាមួយត្រឹមត្រូវពិតប្រាកដ គឺត្រូវចុះស្រាវជ្រាវ ហើយច្បាមយកឱ្យបាន។ «នេះជាចំណុចសំខាន់នៃការប្រមូលទិន្នន័យ ការវិភាគហើយពិគ្រោះយោបល់។ ពិគ្រោះជាមួយតួអង្គនោះតែម្តង។ កុំយកទិន្នន័យនៅក្នុងវិស័យឧស្សាហកម្មកម្មន្តសាល ហើយទៅវាយតម្លៃពីសតិអារម្មណ៍ និងការចង់បានរបស់វិស័យសេវាកម្ម។ ត្រូវតែចុះស្ទង់មតិ (Survey) នៅក្នុងនោះតែម្តង។ នេះជាអ្វីដែលយើងចង់បានហើយយើងធ្វើការងារជាប់ជាប្រចាំ។ បានន័យថា ត្រូវតាមដាន និងត្រួតពិនិត្យនៃការអនុវត្តផែនការគោលនយោបាយ។»។ សម្តេច ហ៊ុន ម៉ាណែត បានថ្លែងបែបនេះដោយ







## ព័ត៌មានពេញនិយម




តើពាក្យ«កតញ្ញូតា និង កតញ្ញូ »មានអត្ថន័យខុសដូចម្តេច? (https://thmeythmey.com/detail/35303)

៣ ថ្ងៃ




អារម្មណ៍មកដាក់ចេញជាមូលដ្ឋានធ្វើគោលនយោបាយ។ ហើយការប្រមូលទិន្នន័យ ក៏មិនត្រូវប្រមូលពី Google យកមកវិភាគ ដោយប្រាកដណាស់យើងត្រូវទាញយកទិន្នន័យផ្លូវការណាមួយ គឺចុះ Survey។»។

រដ្ឋាភិបាលបានចាត់ទុក វិទ្យាស្ថាន CDRI គឺជាធនាគារខួរក្បាល។ មកទល់ពេលនេះ វិទ្យាស្ថាន CDRI មានអាយុ៣៥ឆ្នាំហើយ។ សម្រាប់ការរៀបចំសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២៥ នាពេលនេះ គឺធ្វើឡើងផ្អែកលើសមិទ្ធផលនៃសន្និសីទចក្ខុវិស័យកម្ពុជាកន្លងមក ហើយនឹងបន្តធ្វើជាវេទិកាសម្រាប់ការពិភាក្សាក្នុងន័យស្ថាបនា ក្នុងចំណោមថ្នាក់ដឹកនាំ និងអ្នកពាក់ព័ន្ធសំខាន់ៗ ក្នុងការអភិវឌ្ឍនាពេលអនាគតនៅកម្ពុជា។

គោលបំណងចម្បងនៃសន្និសីទប្រចាំឆ្នាំ២០២៥ គឺដើម្បីវាយតម្លៃពី ភាពខ្លាំង និងភាពខ្សោយ នៃសមិទ្ធកម្មសេដ្ឋកិច្ចរបស់កម្ពុជានាពេលបច្ចុប្បន្ន ដើម្បីកំណត់ទិដ្ឋភាពសំខាន់ៗដែលចាំបាច់ត្រូវកែលម្អ ដើម្បីសម្រេចបាននូវចក្ខុវិស័យអភិវឌ្ឍន៍កម្ពុជា។

សន្និសីទឆ្នាំនេះ ក៏សម្របសម្រួលកិច្ចសន្ទនា ក្នុងចំណោមអ្នកជំនាញជាន់ខ្ពស់ជាតិ និងអន្តរជាតិផងដែរ ដើម្បីយល់ឲ្យកាន់តែច្បាស់អំពីបញ្ហាប្រឈមចំពោះមុខ និងកាលានុវត្តភាព ដើម្បីជួយកម្ពុជា ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ប្រកបដោយប្រសិទ្ធភាព ក្នុងបរិការណ៍នៃស្ថានភាពដែលមានភាពមិនច្បាស់លាស់ អាចប៉ះពាល់ដល់គន្លង នៃការអភិវឌ្ឍនាពេលអនាគតនៅកម្ពុជា។

សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាលើកទី១៦នេះ នឹងផ្ដោតសំខាន់លើដំណើរការ និងទស្សនវិស័យអភិវឌ្ឍន៍របស់កម្ពុជា, បញ្ហាប្រឈមនៃរចនាសម្ព័ន្ធ និងរបៀបវារៈកំណែទម្រង់បន្ទាន់ សម្រាប់កំណើនរយៈពេលវែង






រដ្ឋមន្ត្រីមហាផ្ទៃប្រតិកម្មនឹងពាក្យលែបខាយលើស្ត្រីភេទរបស់ពិធីករប្រដាល់ម្នាក់
(https://thmeythmey.com/detail/145306




(https://thmeythmey.com/detail/55107

ចូរប្រើពាក្យទាំងនេះឲ្យត្រឹមត្រូវ៖ បរវេសនកាល វិស
កាល វ៉ាកង ចូលកង...
(https://thmeythmey.com/detail/55107)

១ ថ្ងៃ




## អ្នកសរសេរអត្ថបទ

អ៊ូ សុខមាន (OU Sokmean) (https://thmeythmey.com/author/126)

កញ្ញា អ៊ូ សុខមាន បានចូលធ្វើការងារនៅស្ថាប័នសារព័ត៌មានឌីជីថលថ្មីៗ នៅឆ្នាំ២០១៨។ កញ្ញាមានជំនាញផ្នែកព័ត៌មានសេដ្ឋកិច្ច កសិកម្ម និងផលិតវីដេអូតាមទូរសព្ទដៃ (MOJO)។ បច្ចុប្បន្ន សុខមាន មានតួនាទីជានិពន្ធនាយិការង៕

សូមចុចត្រង់នេះដើម្បីអានថ្មីៗជាភាសាអង់គ្លេស (Cambodianess.com) (https://cambodianess.com/)




© រក្សាសិទ្ធិដោយ thmeythmey.com

Tag: សេដ្ឋកិច្ច CDRI







(https://thmeythmey.com/detail/50246)

តើពាក្យ«សំឡេង,សម្លេង»មួយណាជាពាក្យត្រឹម
(https://thmeythmey.com/detail/50246)

២ ថ្ងៃ



ច្បាប់ប្រឆាំងមិនទទួលស្គាល់ឧក្រិដ្ឋកម្ម នាសម័យក្រហម ត្រូវបានប្រកាសឱ្យប្រើប្រាស់
(https://thmeythmey.com/detail/145308)

២ ថ្ងៃ

### ហ្វេសប៊ុកផេក






លោក វង្សី វិស្សុត ឱ្យវះកាត់អ្នកបាន អាជ្ញាបណ្ណធ្វើអាជីវកម្មទឹកស្អាត ហើយទុកចោល...

៦ ថ្ងៃ

(http://127.0.0.1:8000/detail



ឧបនាយករដ្ឋមន្ត្រី វង្សី វិស្សុត ៖ មន្ត្រីអនុវត្តគោលនយោបាយត្រូវចុះជួយ កុំចុះរំខាន!...

៦ ថ្ងៃ

(http://127.0.0.1:8000/detail,



ទេសាភិបាលធនាគារជាតិ ពន្យល់ពីកម្រិតអតិផរណានៅកម្ពុជាកើនដល់៦ភាគរយក្នុងខែមករា...

១ សប្តាហ៍

(http://127.0.0.1:8000/detail,



មេទ័ពជើងគោកអាម៉េរិកប្រចាំប៉ាស៊ីហ្វិក វាយតម្លៃខ្ពស់ចំពោះបេសកកម្មកម្ពុជាលើឆាកអន្តរជា...

១ សប្តាហ៍

(http://127.0.0.1:8000/detail




ប៉ះពាល់សុខភាព! ក្រសួងសុខាភិបាល ឱ្យឈប់ប្រើថ្នាំជំនួយផ្លូវភេទ SUPER XL និង...

១ សប្តាហ៍

(http://127.0.0.1:8000/detail,



ពលរដ្ឋខ្មែរ៧,៥លាននាក់ ទទួលបានការគាំពារពីកម្មវិធីជំនួយសង្គម និងប.ស.ស....

២ សប្តាហ៍

(http://127.0.0.1:8000/detail,










Thmey Thmey

1,146,973 followers



Follow Page

Thmey Thmey

18 minutes ago

អាហារសម្រន់បែបសុខភាព៖ ដំណាប់ស្វាយរ
ផែនស្វាយសម្ងួត និងស្វាយក្រៀប មានច្រើន
រសជាតិ អនាម័យខ្ពស់ គ្មានជាតិផ្អែមសិប្បនិ

ក្រុមហ៊ុន ខនហ្វីរេល ជាក្រុមហ៊ុនទំនើបកម្ម
នៅក្នុងប្រទេសកម្ពុជា ដែលបានបំប្លែងផ្លែស្វ




២ សប្តាហ៍ ១ ២ (https://thmeythmey.com/detail/145312?page=2) ២ សប្តាហ៍ ២ សប្តាហ៍ ... ១២

(https://thmeythmey.com/detail/145312?page=12) បន្ទាប់

(https://thmeythmey.com/detail/145312?page=2)

### ទំនាក់ទំនង

(+855) 81 699 329, 12 900 132, 86 654 846

sales@thmeythmey.com

អាសយដ្ឋាន៖ ផ្ទះលេខ២៦៧អា ផ្លូវលេខ ៩៧ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ

### ទាញយកព័ត៌មានគេហទំព័រថ្មីៗ

(https://itunes.apple.com/kh/app/thmeythmey/id833433044?mt=8)

(https://play.google.com/store/apps/details?id=com.cammob.thmeythmey)

### ភ្ជាប់ជាមួយយើងតាមរយៈ

(https://www.facebook.com/

(https://twitter.com/thmeyt

(https://www.youtube.com/c/T

(https://www.youtube.com/c/T

Copyright © 2025 ThmeyThmey (https://thmeythmey.com) - Designed

